## ការអនុវត្តច្បាប់ថ្មីចែងទោសស្រាលជាង (ខ្លឹមសារដកស្រង់)

យល់ឃើញថា៖ ដោយក្រមព្រហ្មទណ្ឌបានចូលជាធរមាន ហើយបទល្មើសនេះ ការកំណត់ទណ្ឌកម្មក្នុងព្រហ្មទណ្ឌមានលក្ខណៈស្រាលជាងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ គប្បីអនុវត្តមាត្រា ១០នៃក្រមព្រហ្មទណ្ឌ (សាលដីកាតុលាការកំពូលលេខ២២៧ ឆ្នាំ២០១១,បទរំលោភសេពសន្ថវៈ, ទំ.៤)។

Considering that: Since the Criminal Code has entered into force and the penalties defined for this offense within the Criminal Code are lighter than those in the Law on Aggravating Circumstances of Felonies, Article 10 of the Criminal Code should be applied.

++++++++

-យល់ឃើញថាច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋនេះ ត្រូវបាននិរាករណ៍ដោយក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៩ហើយ។ ហេតុដូច្នេះ ជនជាប់ចោទឈ្មោះ ស.ល.អ. គប្បីទទួលបានអត្ថប្រយោជន៍នៃការអនុវត្តច្បាប់ថ្មី តាមស្មារតីមាត្រា១០នៃក្រមព្រហ្មទណ្ឌ (សាលដីកាតុលាការកំពូល ព្រហ្មទណ្ឌលេខ៣៣៣ ឆ្នាំ២០១៣, ប្លន់, ទំ.៦)។

Considering that: This Law on Aggravating Circumstances of Felonies has already been repealed by the new 2009 Criminal Code. Consequently, the accused named …should receive the benefit of the application of the new law, in the spirit of Article 10 of the Criminal Code.

++++++++

-យល់ឃើញថា ក្រមព្រហ្មទណ្ឌបានចូលជាធរមាន ហើយទណ្ឌកម្មដែលបានកំណត់ក្នុងបទលួចនៃក្រមព្រហ្មទណ្ឌមានលក្ខណៈស្រាលជាងទណ្ឌកម្ម ដែលបានកំណត់ក្នុងមាត្រា៦នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ ដូច្នេះគប្បីអនុវត្តតាមមាត្រា១០នៃក្រមព្រហ្មទណ្ឌ (សាលដីកាតុលាការកំពូលព្រហ្មទណ្ឌលេខ២៤៣ ឆ្នាំ២០១៣ បទលួច ទំ.៧ )។

Considering that: The Criminal Code has entered into force and the penalties defined for "Theft" in the Criminal Code are lighter than the penalties defined in Article 6 of the Law on Aggravating Circumstances of Felonies. Therefore, Article 10 of the Criminal Code should be applied.

++++++++

យោងតាមមាត្រា១០នៃក្រមព្រហ្មទណ្ឌ តុលាការគប្បីយកបទបញ្ញត្តិនៃច្បាប់ថ្មី ដែលចែងអំពីទោសស្រាលជាងមកអនុវត្ត ដើម្បីជាផលប្រយោជន៍របស់ជនជាប់ចោទ (សាលដីកាព្រហ្មទណ្ឌតុលាការកំពូលលេខ២៨៦ ឆ្នាំ២០១៣ បទក្លែងឯកសារ ទំ.៥ )។

Regarding Article 10 of the Criminal Code, the Court should apply the provisions of the new law that stipulate a lighter penalty for the benefit of the accused.

**កំណត់សំគាល់៖** ខ្លឹមសារដេកស្រង់នេះ ពាក់ព័ន្ធនឹងគោលការណ៍នីតិនុកូលភាព ដែលមានចែង ក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩និងកតិកាសញ្ញា ICCPR មាត្រា១៥។ សូមមើលបន្ថែមអត្ថបទស្រាវជ្រាវមានតភ្ជាប់ទីនេះ។